ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ០០២ សហវ.

ថ្ងៃ ... ខែ ... ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែមករា ឆ្នាំ២០១៨

# សេចក្ដីសម្រេច
## ស្ដីពី
## ការតែងតាំងសមាសភាពគណៈកម្មាធិការវាយតម្លៃសមិទ្ធកម្ម និងការផ្ដល់ការលើកទឹកចិត្តរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ២០១៣ ស្ដីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្ដីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្ដីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ៦១៦ សហវ.ប្រក ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៤ ស្ដីពីការកំណត់គោលការណ៍ យន្តការ នីតិវិធី និងការត្រួតពិនិត្យសម្រាប់ការផ្ដល់ការលើកទឹកចិត្ត ដោយប្រើប្រាស់ប្រាក់រង្វាន់របស់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ ១ -**

ត្រូវបានបង្កើតគណៈកម្មាធិការវាយតម្លៃសមិទ្ធកម្ម និងផ្តល់ការលើកទឹកចិត្តរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ដែលសរសេរអក្សរកាត់ថា " គ.ស.ល.អគរ "។

**ប្រការ ២ -**

គ.ស.ល.អគរ មានសមាសភាព ដូចខាងក្រោម÷

| | | | |
|---|---|---|---|
| ១. | ឯកឧត្តមបណ្ឌិត **គុណ ញឹម** | អគ្គនាយក | ប្រធាន |
| ២. | លោក **ហ៊ុន គីមហេង** | អគ្គនាយករង | អនុប្រធាន |
| ៣. | លោក **នួន ច័ន្ទរិទ្ធ** | អគ្គនាយករង | អនុប្រធាន |
| ៤. | លោក **ខៀវ សំអាន** | អគ្គនាយករង | អនុប្រធាន |
| ៥. | លោកស្រី **ហេង សំអុន** | អគ្គនាយករង | អនុប្រធាន |
| ៦. | លោក **កើត សុផារ៉ា** | ប្រធាននាយកដ្ឋានបង្ការនិងបង្ក្រាបបទល្មើស | សមាជិក |
| ៧. | លោក **ផា អេងទើង** | ប្រធាននាយកដ្ឋានរបបគយ | សមាជិក |
| ៨. | លោក **កែវ សុខឃាង** | ប្រធាននាយកដ្ឋានគ្រប់គ្រងតំបន់រួចពន្ធ | សមាជិក |
| ៩. | លោក **សែ សុឃន** | ប្រធាននាយកដ្ឋានរដ្ឋាករ | សមាជិក |
| ១០. | លោក **សុខ សុចិន្ដា** | ប្រធាននាយកដ្ឋានផែនការ បច្ចេកទេស និងកិច្ចការអន្តរជាតិ | សមាជិក |
| ១១. | លោក **ម៉ូ ម៉ុនណារ៉ា** | អនុប្រធានក្លាប់រួមនាយកដ្ឋានកិច្ចការឲ្យប់សវនកម្ម និងទំនាក់ទំនងសាធារណៈ | សមាជិក |
| ១២. | លោក **គាំ ច័ន្ទកុសល** | អនុប្រធាននាយកដ្ឋានផែនការ បច្ចេកទេស និងកិច្ចការអន្តរជាតិ | សមាជិក |
| ១៣. | លោក **សុខ ឫទ្ធី** | អនុប្រធាននាយកដ្ឋានរដ្ឋបាលនិងគ្រប់គ្រង | សមាជិក |
| ១៤. | លោក **ថេង ម៉ុងហាក់** | អនុប្រធាននាយកដ្ឋានរដ្ឋបាលនិងគ្រប់គ្រង | សមាជិក |
| ១៥. | លោក **ជា ធុទ្ធី** | ជំនួយការនាយកដ្ឋានរដ្ឋបាលនិងគ្រប់គ្រង | សមាជិក |
| ១៦. | លោក **ជា សំអុន** | ប្រធានការិយាល័យគណនេយ្យនិងហិរញ្ញវត្ថុ | សមាជិក |

**ប្រការ ៣ -**

**គ.ស.ល.អគរ** មានមុខងារនិងភារកិច្ច ដូចខាងក្រោម ÷

- ពិនិត្យនិងអនុម័តលើសេចក្តីព្រាងផែនការលើកទឹកចិត្ត និងផែនការអភិវឌ្ឍស្ថាប័នរបស់គ្រប់អង្គភាពក្រោមឱវាទអគ្គនាយដ្ឋានគយនិងរដ្ឋាករកម្ពុជា។
- ពិនិត្យនិងសម្រេចលើការផ្តល់ការលើកទឹកចិត្ត ផ្អែកលើផែនការលើកទឹកចិត្ត និងផែនការអភិវឌ្ឍស្ថាប័នដែលបានអនុម័ត។
- ត្រួតពិនិត្យនិងវាយតម្លៃលើវឌ្ឍនភាពនៃការអនុវត្តផែនការលើកទឹកចិត្ត និងផែនការអភិវឌ្ឍស្ថាប័នរបស់គ្រប់អង្គភាពក្រោមឱវាទអគ្គនាយដ្ឋានគយនិងរដ្ឋាករកម្ពុជា។

**ប្រការ ៤ -**

អនុប្រធាន និងសមាជិក នៃ គ.ស.ល.អគរ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន គ.ស.ល.អគរ។ ប្រធាន គ.ស.ល.អគរ អាចប្រគល់សិទ្ធិជូនអនុប្រធានដឹកនាំកិច្ចប្រជុំជំនួស និងអញ្ជើញថ្នាក់ដឹកនាំអង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ឱ្យចូលរួមប្រជុំតាមការចាំបាច់។

**ប្រការ ៥ -**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៦ -**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងសាមីជនដូចមានចែងក្នុងប្រការ២ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

បណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល ÷**
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ដូចប្រការ ៦
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ